# ក.២. សត្វល្អិតចង្រៃសំខាន់ៗ

# ដង្កូវហ្វូង

## ក.២.១. Rice Army Worm (*Mythimna separata*)



(រូបភាព ៥៧) កូនដង្កូវ

**ការពណ៌នា :**

កូនដង្កូវមានពណ៌ខៀវ ហើយប្រែទៅជាពណ៌ត្នោត និងមានស្នាមឆ្នូតនៅលើខ្នង ។ ដឹកដឿមានពណ៌ត្នោត និងសំងំលាក់ខ្លួននៅក្នុងដីជម្រៅប្រមាណ ២ ស.ម ។ មេអំបៅមានពណ៌ត្នោត និងមានស្នាមអុចៗពណ៌ខ្មៅនៅពីលើស្លាបខាងក្រៅ ឯស្លាបខាងក្នុងមានពណ៌ត្នោតព្រលែត ។



(រូបភាព ៥៨) ដង្កូវពេញវ័យ



(រូបភាព ៥៩) ដឹកដឿ

**ការបំផ្លាញ :**

ដង្កូវស៊ីបំផ្លាញស្លឹក និងកាត់កួរស្រូវ ។

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- វត្តមានរបស់ដំណាំដែលជាជម្រករបស់ដង្កូវហ្វូង ។
- ក្នុងរយៈពេលដែលមានការរាំងស្ងួត ហើយមានភ្លៀងធ្លាក់ខ្លាំងនៅពេលបន្ទាប់ ។



(រូបភាព ៦០) មេអំបៅ

**ដំណាំជម្រក :**

ស្រូវ ពោត និងដំណាំដទៃទៀត ។

# សង្កើចខ្មៅ

## ក.២.២. Black Bug (*Scotinophara coarctata*)

**អាវុធពណ៌នា :**

ពងរបស់សង្កើចខ្មៅមានរាងមូល ពណ៌ផ្កាឈូក ។ សត្វពេញវ័យពងនៅលើស្លឹក ឬដើមដែលស្ថិតនៅផ្នែកខាងក្រោមក្បែរផ្ទៃទឹក ។ កូនសង្កើច មានពណ៌ត្នោត ឯសង្កើចពេញវ័យមានពណ៌ត្នោត ឬពណ៌ខ្មៅរលើប ។ នៅពេលថ្ងៃវាស្ថិតនៅលើដើមផ្នែកខាងក្រោម និងឡើងមកលើដើមផ្នែកខាងលើនៅពេលយប់ ។



(រូបភាព ៦១) មេពញ្ញវ័យ និងពងរបស់វា



(រូបភាព ៦២) កូនសង្កើចខ្មៅ

**ការបំផ្លាញ :**

សត្វពេញវ័យ និងកូនរបស់វាបឺតជញ្ជក់រុក្ខរស់ពីដើម ។ ពួកវាចូលចិត្តជញ្ជក់ត្រង់គល់ស្រូវ ដែលធ្វើឱ្យស្រូវមានសភាពអន់ដើម ។ ការបំផ្លាញធ្ងន់ធ្ងរអាចបណ្តាលឱ្យស្រូវងាប់ កួរស្រូវស្កក គ្រាប់ស្រូវមិនពេញល្អ ឬស្កក និងធ្វើឱ្យស្លឹកមានពណ៌ត្នោត ឬស្លោកងាប់ ។

**កត្តាដែលធ្វើឱ្យសត្វល្អិតកើតឡើងខ្លាំង :**

- តំបន់ស្រោចស្រពដោយទឹកភ្លៀង និងតំបន់ដីសើមដែលមានប្រព័ន្ធស្រោចស្រព ។
- ស្រែដែលពុំមានការបង្ហូរទឹកចេញ ។
- ក្នុងតំបន់ដែលធ្វើការដាំដុះដំណាំស្រូវមិនបានស្រុះគ្នា នៅក្នុងកំឡុងពេលមួយដូចគ្នា ។
- ស្រែដែលមានដង់ស៊ីតេដើមស្រូវខ្ពស់ហួសហេតុ ។
- ប្រើប្រាស់បរិមាណអាសូតច្រើន ។
- វត្តមានដំណាំដែលអាចជាជម្រកដុះនៅក្បែរ ។
- ក្នុងកំឡុងពេលយប់មានព្រះចន្ទ ។




(រូបភាព ៦៣) សង្កើចខ្មៅពេញវ័យ

**ដំណាំជម្រក :** ស្រូវ និង ពោត ។

## មមាចត្នោត

## ក.២.៣. Brown Planthopper (*Nilaparvata lugens*)



(រូបភាព ៦៤) ពងរបស់មមាចត្នោត

**ការពណ៌នា :**

ពងមមាចត្នោតមានពណ៌ស ។ កូនរបស់វាមានពណ៌ក្រែម និងពណ៌ត្នោតស្លេក ។ មមាចពេញវ័យមានពីរប្រភេទ គឺ ប្រភេទស្លាបវែង និងស្លាបខ្លី ។ ជាទូទៅនៅរដូវប្រាំងមានមមាចត្នោតច្រើនជាងនៅរដូវវស្សា ។

ជាធម្មតា គេឃើញវានៅក្នុងស្រែដែលស្រោចស្រពដោយទឹកភ្លៀង និងស្រែដែលស្រោចស្រពដោយប្រពន្ធ័ស្រោចស្រព នៅក្នុងដំណាក់កាលស្រូវបង្កកំណើត ។



(រូបភាព ៦៥) កូនមមាចត្នោត

**ការបំផ្លាញ :**

មមាចត្នោតពេញវ័យ និងកូនរបស់វាជញ្ជក់រុក្ខរស់របស់ដើម ស្លឹក និងស្រទបស្លឹកដោយធ្វើអោយដើមឡើងពណ៌លឿង ។

ដើមស្រូវអាចឆេះខ្លោច ឬងាប់តែម្តងនៅពេលមានការបំផ្លាញខ្លាំង ។

មមាចត្នោតជាភ្នាក់ងារចម្លងវីរុសម្យ៉ាងដែលបង្កជាជំងឺតឿស្មៅ និងជំងឺតឿរួញស្លឹក ។

ដើមដែលទទួលការបំផ្លាញពីមមាចត្នោត ងាយនឹងទទួលរងការកើតជំងឺផ្សេងៗដែលបណ្តាលមកពីមេរោគផ្សិត និងបាក់តេរី ។

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- តំបន់ដែលទទួលការស្រោចស្រពដោយទឹកភ្លៀង និងតំបន់ដីសើមដែលមានប្រព័ន្ធស្រោចស្រព ។
- ស្រែដែលមានទឹកដក់ជាប្រចាំ ។
- ស្រែដែលមានម្លប់បាំង និងមានសំណើមខ្ពស់ ។
- ស្រែដែលមានដង់ស៊ីតេដើមស្រូវច្រើនហួសហេតុ ។
- ប្រើប្រាស់ជីអាសូតច្រើនហួសកំរិត ។
- ការប្រញាប់បាញ់ថ្នាំកសិកម្ម នៅក្នុងដំណាក់កាលដំបូងនៃការលូតលាស់របស់ស្រូវ ។



(រូបភាព ៦៦) មមាចពេញវ័យ (ស្លាបខ្លី និង ស្លាបវែង)

**ដំណាំជម្រក :**

ស្រូវ ។

# ខ្យងពណ៌មាស

## ក.២.៤. Golden Apple Snail *(Pomacea canaliculata)*



(រូបភាព ៦៧) ពងខ្យង

**ការពណ៌នា :**

ពងខ្យងមាស មានពណ៌ផ្កាឈូកខ្ចី ។ ខ្យងពេញវ័យមានពណ៌លឿង ឬពណ៌ត្នោតចាស់ ។ ដំណាក់កាលដែលបំផ្លាញ ខ្លាំងបំផុតគឺនៅពេលដែលវាមានទំហំពី ១០-៤០ មម ។ វាមានសកម្មភាពនៅពេលយប់ ។



(រូបភាព ៦៨) កូនខ្យង

**ការបំផ្លាញ :**

- ស៊ីបំផ្លាញកោសិការុក្ខជាតិ ។
- ធ្វើឱ្យបាត់បង់ចំនួនដើមរុក្ខជាតិ ។



(រូបភាព ៦៩) ខ្យងពេញវ័យ និងពងរបស់វា

**កត្តាធ្វើឱ្យសត្វល្អិតមានការលូតលាស់ខ្លាំង :**

- តំបន់ដីស្ងួត និងដីសើម ។
- តំបន់ដែលមានប្រព័ន្ធស្រោចស្រពដូចជា ប្រឡាយ ស្ទឹង ទន្លេ ។
- វត្តមានដំណាំជម្រក ។
- ពេលកូនរុក្ខជាតិនៅតូច ។
- ស្រែដែលដាំទឹកជាប្រចាំ ។
- វាអាចដកដង្ហើមនៅលើគោក និងនៅក្នុងទឹក ។
- វាអាចរស់នៅក្នុងគ្រប់លក្ខខណ្ឌ ។

**ដំណាំជម្រក :**

ស្រូវ ត្រាវ និងដំណាំដទៃទៀត ។

# មមាចខៀវ

## ក.២.៥. Green Leafhopper *(Nephotettix virescens)*



(រូបភាព ៧០) ពងរបស់មមាចខៀវ

**ការពណ៌នា :**

ពងរបស់វាមានរាងមូលទ្រវែង ពណ៌ស ឬលឿងខ្ចី ដែលបន្ទាប់មកវាប្រែទៅជាពណ៌ត្នោត និងមានស្នាមអុចពណ៌ក្រហមដូចគ្រាប់ភ្នែក ។ កូនមមាចមានពណ៌លឿងខ្ចី មានបន្ទាតូចៗនៅលើខ្នងត្រង់ផ្នែកពោះ ។ មមាចពេញវ័យមានរាងតូចស្តើង មានពណ៌បៃតង មានស្នាមខ្មៅនៅលើក្បាល និងលើស្លាប ។ ជាទូទៅវាបឺតជញ្ជក់សារធាតុចិញ្ចឹមពីរុក្ខជាតិនៅផ្នែកខាងលើដើម ។

**ការបំផ្លាញ :**

-បឺតជញ្ជក់រុក្ខរស់ពីដើមស្រូវ ។

- ជាភ្នាក់ងារចម្លងជំងឺ ដូចជាជំងឺទង់គ្រោ និងជំងឺតឿលឿងជាដើម ។




(រូបភាព ៧១) កូនរបស់មមាចខៀវ

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- វត្តមានរបស់ស្មៅ ដែលជាជម្រករបស់វាដុះ នៅតាមប្រឡាយទឹក និងតាមភ្លឺស្រែ ។

- វត្តមាននៃស្រូវដុះសារឬម្ញូរ ។

- នៅពេលមានពន្លឺថ្ងៃ មានភ្លៀងធ្លាក់តិច និងសីតុណ្ហភាពក្តៅខ្លាំង ។

- ការប្រើជីអាសូតហួសកំរិត ។



(រូបភាព ៧២) មមាចខៀវពេញវ័យ

**ដំណាំជម្រក :**

ស្រូវ ពោត អំពៅ និងដំណាំដទៃទៀត ។

# ដង្កូវមូរស្លឹក

## ក.២.៦. Leaf Folder (*Cnaphalocrocis medinalis)*



(រូបភាព ៧៣) កូនដង្កូវកំពុងទាញជាយស្លឹកបញ្ចូលគ្នា ដោយប្រើសរសៃសូត្ររបស់វា

**ការពណ៌នា :**

នៅដំណាក់កាលដំបូង ដង្កូវមានពណ៌លឿង បន្ទាប់មកវាមានពណ៌លឿងលាយបៃតងនៅពេលវាធំ និងមានប្រវែងពី ១២ ទៅ ២៥ ម.ម ។ ដង្កូវតែមួយអាចមូរស្លឹកពី ២ ទៅ៤ស្លឹក ។ ដឹកដឿរបស់វាមានប្រវែងពី ៩ ទៅ១២ ម.ម ហើយសំងំលាក់ខ្លួននៅក្នុងស្លឹកដែលវាបានមូរចូលគ្នា ។ មេអំបៅមានពណ៌លឿងចាស់ វាតែងបង្ហាញខ្លួននៅពេលល្ងាច ហើយធ្វើការពងនៅពេលយប់ ។



(រូបភាព ៧៤) ដង្កូវស៊ីផ្ទៃកខាងក្នុងស្លឹកដែលវាបានទាញភ្ជាប់គ្នា



(រូបភាព ៧៥) ដឹកដឿនៅក្នុងសំណាញ់សូត្រ

**ការបំផ្លាញ :**

ដង្កូវមូរស្លឹកបញ្ចូលគ្នាធ្វើជាសំបុក និងសំងំខ្លួននៅផ្ទៃកខាងក្នុង ហើយស៊ីបំផ្លាញកោសិកាស្លឹក ដែលធ្វើឱ្យស្លឹកដែលវាស៊ីបំផ្លាញមានស្នាមឆ្នូតថ្លា ។


(រូបភាព ៧៦) មេអំបៅ

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- ការប្រើប្រាស់ជីច្រើនពេក ។
- វាលស្រែដែលមានម្លប់បាំង និងវាលស្រែដែលមានសំណើមខ្ពស់ ។
- ស្រែដែលមានស្មៅដុះច្រើន ។

**ដំណាំជម្រក :**

ស្រូវ ពោត ដូង ចេក អំពៅ ថ្នាំជក់ និងដំណាំដទៃទៀត ។

# ស្រីងជញ្ជក់ទឹកដោះ

## ក.២.៧. Rice Bug *(Leptocorisa oratorius)*



(រូបភាព ៧៧) ពង



(រូបភាព ៧៨) កូនស្រីង

**ការពណ៌នា :**

ពងមានរាងមូលទ្រវែង ពណ៌ក្រហមក្រម៉ៅភ្លឺរលោង ។
កូនស្រីងមានពណ៌ស្លេក និងមានអង់តែនវែង
តែក្រោយមក វាប្រែទៅជាពណ៌លឿងលាយបៃតង ។
ស្រីងពេញវ័យមានជើងវែង និងមានដងខ្លួនវែងស្តើង ។
វាចេញរកស៊ី នៅពេលព្រឹកព្រលឹម និងពេលល្ងាច ។



(រូបភាព ៧៩) កូនស្រីង



(រូបភាព ៨០) ស្រីងពេញវ័យ

**ការបំផ្លាញ :**

ស្រីងធ្វើការបឺតជញ្ជក់ទឹកដោះពីគ្រាប់ស្រូវ
ដោយធ្វើឱ្យគ្រាប់ស្រូវមានទំហំតូច មានស្នាមអុច
និងមានទម្រង់មិនពេញលេញ ឬខូចតែម្តង ។

**ដំណាំជម្រក :**

ស្រូវ ត្របែក ស្វាយ តែ
និងដំណាំដទៃទៀត ។

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- ការដាំដុះស្រូវធ្វើឡើងមិនបានស្រុះគ្នាក្នុងអំឡុងពេលតែមួយ ។
- អាកាសធាតុក្តៅ មេឃស្រទុំ និងមានភ្លៀងរលឹម ។
- ដំណាក់កាលស្រូវចាប់ផ្តើមផ្កា ដល់ដំណាក់កាលស្រូវដាក់ទឹកដោះ ។




(រូបភាព ៨១) ស្រីងពេញវ័យ



(រូបភាព ៨២) ស្រីងពេញវ័យ

# ដង្កូវបំពង់កាត់ស្លឹក

## ក.២.៨. Rice Case Worm (*Nymphula depunctalis*)



(រូបភាព ៨៣) ពង


(រូបភាព ៨៤) ដង្កូវ



(រូបភាព ៨៥) ដឹកដឿ

**ការពណ៌នា :**

មេអំបៅពងនៅក្រោមស្លឹក ។ ដង្កូវមានពណ៌បៃតងព្រលែត និងមានក្បាលពណ៌ត្នោតស្រាល ។
ដឹកដឿមានពណ៌លឿងស្រាល ហើយប្រែទៅជាពណ៌ប្រាក់នៅពេលវាចាស់ ។
មេអំបៅមានពណ៌ស និងមានស្នាមក្រវិចក្រវៀនពណ៌ត្នោតស្រាល ។

**ការបំផ្លាញ :**

- ដង្កូវកាត់បំផ្លាញចុងស្លឹក និងមូរស្លឹកដែលវាកាត់ជាបំពង់តូចៗ ។
- ស្លឹកដែលវាកាត់មានលក្ខណៈដូចជាកាំជណ្ដើរ ។

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- ស្រែដែលដក់ទឹក ។
- ស្ទូងសំណាបខ្ចី ។
- តំបន់ដីសើម និងមជ្ឈដ្ឋានដែលមានប្រពន្ធ័ស្រោចស្រព ។


(រូបភាព ៨៦) មេអំបៅ

**ដំណាំជម្រក :**

ស្រូវ ពពួកកក់ និងដំណាំដទៃទៀត ។

# ទ្រីប

## ក.២.៩. Rice Thrip *(Stenchaetothrips biformis)*


(រូបភាព ៨៧) ពង និងកូនតូច នៅដំណាក់កាលដំបូង


(រូបភាព ៨៨) កូនពេញវ័យ


(រូបភាព ៨៩) ដឹកដឿនៅដំណាក់កាលដំបូង


(រូបភាព ៩០) ដឹកដឿពេញវ័យ


(រូបភាព ៩១) ទ្រីបពេញវ័យ

**ការពណ៌នា :**

ពងរបស់វាមានរាងមូលតូចល្អិត ពណ៌សថ្លា និងប្រែជាពណ៌លឿងព្រលែតនៅពេលជិតញាស់ ។ កូនទ្រីបមានសំបុរត្នោត ។ មេពេញវ័យមានប្រវែងពី ១-២ ម.ម ពណ៌ត្នោតចាស់ ខ្លះមានស្លាប និងខ្លះទៀតគ្មានស្លាប ។

**ការបំផ្លាញ :**

ទ្រីបបំផ្លាញកោសិការបស់ស្លឹកខ្ចី ដើម ដោយបឺតជញ្ជក់សារធាតុចិញ្ចឹមពីស្លឹក ដើម និងកួរស្រូវ ។ ស្លឹកដែលត្រូវវាបំផ្លាញមានស្នាមខ្សែពណ៌សថ្លាឆ្នុះ រមូរចូលគ្នា និងឡើងពណ៌លឿងត្នោត ។ វាអាចបណ្តាលឱ្យដើមស្រូវក្រិន ឬអាចងាប់តែម្តង នៅពេលមានការបំផ្លាញខ្លាំង ។
ចំពោះកួរស្រូវដែលទទួលរងការបំផ្លាញវិញអាចនឹងស្កក ។
ទ្រីបធ្វើការបំផ្លាញខ្លាំងនៅក្នុងដំណាក់កាលសំណាប ដំណាក់កាលបែកគុម្ព និងនៅពេលស្រូវចេញផ្កា ។

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង :**

- អាកាសធាតុរាំងស្ងួត ។
- ស្រែគ្មានទឹក ។
- វត្តមានរបស់ស្មៅដែលស្ថិតនៅក្នុងអំបូរក្រាមីនេ ។

**ដំណាំជម្រក** : ស្រូវ ពោត និងរុក្ខជាតិដទៃទៀត ។

# ជន្លួចស៊ីរូងដើម

## ក.២.១០. Yellow Stem Borer (*Scirpophaga incertulas*)


(រូបភាព ៥២) កន្សោមពង


(រូបភាព ៥៣) កូនដង្កូវទើបញាស់


(រូបភាព ៥៤) កូនដង្កូវ

**ការពណ៌នា :**

ពងមានពណ៌ស រាងសំប៉ែតទ្រវែង ដែលត្រូវបានគ្របដណ្ដប់ដោយរោមពណ៌ត្នោតរបស់មេអំបៅញី ។ ដង្កូវមានពណ៌លឿងគ្មានរោម និងមានក្បាលពណ៌ទឹកក្រូច ។ ដឹកដឿសំងំខ្លួននៅក្នុងដើម ។ មេអំបៅញីមានពណ៌លឿងស្រាល និងមានស្នាមចំណុចពណ៌ខ្មៅមួយនៅលើស្លាបនីមួយៗរបស់វា ។ ចំណែកមេអំបៅឈ្មោលវិញ មានមាឌតូចជាងមេអំបៅញី មានពណ៌លឿងចាស់ និងមានស្នាមខ្មៅចំនួនពីរនៅលើស្លាបនីមួយៗរបស់វា ។


(រូបភាព ៥៥)
កូនដង្កូវស៊ីរូងផ្នែកខាងក្នុងដើម


(រូបភាព ៥៦) ដង្កូវចំណាស់


(រូបភាព ៥៧) ដឹកដឿ

**ការបំផ្លាញ :**

- ធ្វើឱ្យបណ្ដូលស្រូវងាប់ ។
- ធ្វើឱ្យកួរស្រូវស្កក ។

**កត្តាដែលធ្វើឱ្យសត្វល្អិតលូតលាស់ខ្លាំង:**

- ស្រែដែលធ្វើការដាំដុះក្រោយគេ ។
- វត្តមានរបស់គល់ជញ្ជ្រាំងនៅលើវាលស្រែ ។

**ដំណាំជម្រក** : ស្រូវ ពោត និងដំណាំដទៃទៀត ។


(រូបភាព ៥៨) មេអំបៅញី


(រូបភាព ៥៩) មេអំបៅឈ្មោល